ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

លេខ: ៧១ អយក.សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មការអភិវឌ្ឍន៍ធនធានគ្រូបង្រៀន

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស០១២/០៦១៨/រកម/ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ៧៣ អនក្រ.បក ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការដំឡើងកម្រិតបណ្តុះបណ្តាល និងការបញ្ចូលមជ្ឈមណ្ឌលគរុកោសល្យភូមិភាគរាជធានីភ្នំពេញ និងសាលាគរុកោសល្យនិងវិក្រឹតការរាជធានីភ្នំពេញ ទៅជាវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការដំឡើងកម្រិតបណ្តុះបណ្តាល និងការបញ្ចូលមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តបាត់ដំបង និងសាលាគរុកោសល្យនិងវិក្រឹតការខេត្តបាត់ដំបង ទៅជាវិទ្យាស្ថានគរុកោសល្យបាត់ដំបង
- បានឃើញអនុក្រឹត្យលេខ១៤៣ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០២០ ស្តីពីការផ្ទេរការគ្រប់គ្រងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគចំនួន៤ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគឦសាននៅខេត្តស្ទឹងត្រែង សាលាគរុកោសល្យនិងវិក្រឹតការខេត្តចំនួន១៥ និងសាលាអនុវត្តន៍ឱ្យមកស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំ យុវជន និងកីឡា
- យោងតាមការចាំបាច់របស់ក្រសួងអប់រំ យុវជន និងកីឡា



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ: www.moeys.gov.kh

## សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើតគណៈកម្មការអភិវឌ្ឍន៍ធនធានគ្រូបង្រៀន ដើម្បីគ្រប់គ្រងគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន និងសាលាអនុវត្តន៍ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំ យុវជន និងកីឡា លើកលែងតែគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនអប់រំកាយនិងកីឡា គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនបណ្តុះបណ្តាលអប់រំវិជ្ជាជីវៈ និងវិទ្យាស្ថានជាតិអប់រំពិសេស។

**ប្រការ២ .-**

គណៈកម្មការអភិវឌ្ឍន៍ធនធានគ្រូបង្រៀនមានសមាសភាព ដូចខាងក្រោម៖

| | |
|---|---|
| ១. រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា | ប្រធាន |
| ២. រដ្ឋលេខាធិការទទួលបន្ទុកការងារបណ្តុះបណ្តាល | អនុប្រធានប្រចាំការ |
| ៣. រដ្ឋលេខាធិការ ១(មួយ)រូប | អនុប្រធាន |
| ៤. អនុរដ្ឋលេខាធិការ៣(បី)រូប | សមាជិក |
| ៥. អគ្គាធិការនៃអគ្គាធិការដ្ឋាន | សមាជិក |
| ៦. អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំ | សមាជិក |
| ៧. អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ | សមាជិក |
| ៨. អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយ និងផែនការ | សមាជិក |
| ៩. អគ្គនាយកនៃអគ្គនាយកដ្ឋានយុវជន | សមាជិក |
| ១០. អគ្គនាយកនៃអគ្គនាយកដ្ឋានឧត្តមសិក្សា | សមាជិក |
| ១១. អគ្គនាយកនៃអគ្គនាយកដ្ឋានកីឡា | សមាជិក |
| ១២. ប្រធាននាយកដ្ឋានបុគ្គលិក | សមាជិក |
| ១៣. ប្រធាននាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ | សមាជិក |
| ១៤. ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ | សមាជិក |
| ១៥. ប្រធាននាយកដ្ឋានសម្ភារៈ និងទ្រព្យសម្បត្តិរដ្ឋ | សមាជិក |
| ១៦. ប្រធាននាយកដ្ឋានផែនការ | សមាជិក |
| ១៧. ប្រធាននាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ | សមាជិក |
| ១៨. តំណាងគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន២(ពីរ)រូប | សមាជិក |

សមាសភាពជាក់ស្តែងនៃគណៈកម្មការអភិវឌ្ឍន៍ធនធានគ្រូបង្រៀន កំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។

**ប្រការ៣ .-**

**គណៈកម្មការអភិវឌ្ឍន៍ធនធានគ្រូបង្រៀន** មានភារកិច្ចដូចខាងក្រោម៖

- ដឹកនាំ សម្របសម្រួល ត្រួតពិនិត្យ និងផ្តល់យោបល់លើការអនុវត្តគោលនយោបាយ និងផែនការអភិវឌ្ឍគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន និងផែនការអភិវឌ្ឍន៍ធនធានគ្រូបង្រៀន

- សម្របសម្រួល ត្រួតពិនិត្យ និងផ្តល់យោបល់លើការគ្រប់គ្រងគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន និងសាលាអនុវត្តន៍
- តម្រង់ទិសក្នុងការរៀបចំនិងអនុវត្តផែនការយុទ្ធសាស្ត្រនិងផែនការសកម្មភាពរបស់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន។

គណៈកម្មការអភិវឌ្ឍន៍ធនធានគ្រូបង្រៀន ត្រូវប្រជុំពីរដងក្នុងមួយឆ្នាំ ដើម្បីពិនិត្យតាមដានពីប្រសិទ្ធភាពការងារ និងកិច្ចប្រជុំវិសាមញ្ញផ្សេងទៀតតាមការចាំបាច់។

គណៈកម្មការអភិវឌ្ឍន៍ធនធានគ្រូបង្រៀន មានលេខាធិការដ្ឋានដែលមានទីតាំងនៅក្នុងនាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ ជាសេនាធិការ។

**ប្រការ៤ .-**

លេខាធិការដ្ឋាននៃគណៈកម្មការអភិវឌ្ឍន៍ធនធានគ្រូបង្រៀន មានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| ១. រដ្ឋលេខាធិការទទួលបន្ទុកការងារបណ្តុះបណ្តាល | ប្រធាន |
| ២. អនុរដ្ឋលេខាធិការទទួលបន្ទុកការងារបណ្តុះបណ្តាល | អនុប្រធាន |
| ៣. អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំ | អនុប្រធាន |
| ៤. អគ្គនាយករង នៃអគ្គនាយកដ្ឋានអប់រំ (ទទួលបន្ទុក) | សមាជិក |
| ៥. ប្រធាននាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ | សមាជិកប្រចាំការ |
| ៦. តំណាងនាយកដ្ឋានបុគ្គលិក | សមាជិក |
| ៧. តំណាងនាយកដ្ឋានហិរញ្ញវត្ថុ | សមាជិក |
| ៨. តំណាងនាយកដ្ឋានសម្ភារៈ និងទ្រព្យសម្បត្តិរដ្ឋ | សមាជិក |
| ៩. តំណាងអង្គភាពពាក់ព័ន្ធ៣(បី)រូប | សមាជិក |

សមាសភាពជាក់ស្តែងនៃលេខាធិការដ្ឋាន កំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។

**ប្រការ៥ .-**

លេខាធិការដ្ឋាននៃគណៈកម្មការអភិវឌ្ឍន៍ធនធានគ្រូបង្រៀន មានភារកិច្ចដូចខាងក្រោម៖

- រៀបចំកម្មវិធីការងារ និងធ្វើផែនការសកម្មភាពរបស់គណៈកម្មការអភិវឌ្ឍន៍ធនធានគ្រូបង្រៀន
- រៀបចំនិងគ្រប់គ្រងគម្រោងថវិកាសម្រាប់ការគាំទ្រកិច្ចដំណើរការរបស់គណៈកម្មការ និងលេខាធិការដ្ឋាន
- ធ្វើទំនាក់ទំនង សម្របសម្រួល និងសហការជាមួយអង្គភាពពាក់ព័ន្ធ
- គ្រប់គ្រង និងរក្សាទុកឯកសារពាក់ព័ន្ធដែលទទួលបានពីគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន និងនាយកដ្ឋានពាក់ព័ន្ធ
- សិក្សាបញ្ហាប្រឈមនិងផលប៉ះពាល់ ព្រមទាំងលើកសំណើដោះស្រាយ ជូនគណៈកម្មការពិនិត្យនិងសម្រេច
- ធ្វើរបាយការណ៍បូកសរុបការងារតាមការកំណត់របស់គណៈកម្មការ
- អនុវត្តភារកិច្ចផ្សេងទៀតតាមការណែនាំ ឬការចាត់តាំងរបស់គណៈកម្មការ។

ប្រធានលេខាធិការដ្ឋាន អាចស្នើសុំទៅគណៈកម្មការអភិវឌ្ឍន៍ធនធានគ្រូបង្រៀនបង្កើតផ្នែកមួយចំនួនតាមការចាំបាច់។

**ប្រការ៦ .-**

អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយនិងផែនការ អគ្គនាយកនៃអគ្គនាយកដ្ឋានឧត្តមសិក្សា អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំ អគ្គនាយកនៃអគ្គនាយកដ្ឋានកីឡា អគ្គនាយកនៃអគ្គនាយកដ្ឋានយុវជន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានគ្រប់អង្គភាពពាក់ព័ន្ធ ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ៧រោច ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៦ ខែ ៥ ឆ្នាំ២០២០

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
- គ្រប់អង្គភាពក្រោមឱវាទក្រសួង

"ដើម្បីជូនជ្រាប"

- ដូចប្រការ៦

"ដើម្បីអនុវត្ត"

- កាលប្បវត្តិ
- ឯកសារ នា.នីតិកម្ម